## *តើត្រូវព្យាបាលយ៉ាងដូចម្តេច?*

បច្ចុប្បន្ននេះមិនទាន់រកឃើញមូលហេតុនៃអូទីស្សឹមទេ ហើយក៏គ្មានការព្យាបាលឱ្យជាសះស្បើយបានដែរ។ ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាលទាន់ពេលវេលាអាចជួយឱ្យកុមារ អូទីស្សឹមបានប្រសើរឡើង។ មិនមានការព្យាបាល អូទីស្សឹមជាក់លាក់តែមួយមុខទេ។ ជាទូទៅការព្យាបាល ផ្តោតទៅលើការគ្រប់គ្រោងបញ្ហាអាកប្បកិរិយា និងបង្កើនជំនាញក្នុងការរៀនសូត្រ។

*គ្រូពេទ្យរបស់អ្នកនឹងផ្តល់នូវពត៌មាន ព្រមទាំងបញ្ជូនកូនលោកអ្នកទៅរកធនធានដែលអាចធ្វើឱ្យគាត់មានការរីកចំរើនឡើង។*

***ការធ្វើអន្តរាគមន៍ទាន់ពេលវេលា៖*** យុទ្ធសាស្ត្រអន្តរាគមន៍ទាន់ពេលវេលា រួមមានការបង្រៀនកុមារឱ្យចេះកត់សម្គាល់នូវអ្វីដែលកំពុងកើតឡើងនៅក្នុងបរិយាកាសរបស់ពួកគាត់ តាមរយៈការប្រើប្រាស់រូបភាព ឱ្យចេះយកចិត្តទុកដាក់ ផ្ចង់អារម្មណ៍ គ្រាប់តាម ហើយក្រោយមកឈានទៅរក ជំនាញទំនាក់ទំនង។



## *គន្លឹះសម្រាប់ឪពុកម្តាយ*

⇒ រៀនឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន

⇒ ផ្តល់នូវរចនាសម្ព័ន្ធ និងទម្លាប់ជាប្រចាំ

⇒ ភ្ជាប់ទំនាក់ទំនងជាមួយឪពុកម្តាយរបស់កុមារអូទីស្សឹមដទៃទៀត

⇒ រកជំនួយពីអ្នកឯកទេស

⇒ ចំណាយពេលវេលាសម្រាប់ខ្លួនឯង និងសមាជិកគ្រួសារផ្សេងទៀត

ការមានកូនអូទីស្សឹមមានផលប៉ះពាល់ដល់គ្រួសារទាំងមូល។ វាអាចមានបណ្តាលឱ្យមានភាពតានតឹង ចំណាយពេល វេលាច្រើន និងចំណាយថវិកាខ្ពស់។ ការយកចិត្តទុកដាក់ដល់សុខភាពរាងកាយ និងផ្លូវចិត្តរបស់ក្រុមគ្រួសារទាំងមូលគឺមានសារៈសំខាន់។

***ពត៏មានបន្ថែមសូមទាក់ទង***

***មន្ទីរពេទ្យកុមារជាតិ***

*លេខ១០០ មហាវិថីសហព័ន្ធរុស្សី*

*រាជធានីភ្នំពេញ*

# មន្ទីរពេទ្យកុមារជាតិ

National Pediatric Hospital

# *អូទីស្សឹម*



ផ្នែក

កង្វះអាហារូបត្ថម្ភ ប្រព័ន្ធប្រសាទ និងផ្លូវចិត្ត

## តើអូទីស្សឹម ឬ ASD ជាអ្វី?

**អូទីស្សឹម** គឺជាពិការភាពខាងការអភិវឌ្ឍដែលអាចបណ្តាលឱ្យមានការផ្លាស់ប្តូរនូវ ពុទ្ធិបញ្ញា ជំនាញទំនាក់ទំនង ជំនាញសង្គម និងអាកប្បកិរិយា។

## តើអូទីស្សឹមមានរោគសញ្ញាដូចម្តេចខ្លះ?

កុមារអូទីស្សឹមមានសមត្ថភាព និងលក្ខណៈសំគាល់ផ្សេងៗខុសគ្នាច្រើន។ រោគសញ្ញាអាចមានការប្រែប្រួលពីកំរិតស្រាលទៅ កំរិតធ្ងន់ធ្ងរ ហើយជារឿយៗមានការផ្លាស់ប្តូរទៅតាមពេលវេលា។

**រោគសញ្ញានៃអូទីស្សឹមរួមមាន៖**

*បញ្ហាទំនាក់ទំនង៖*



♦ អាចមិនចេះនិយាយ ឬចង្អុលបង្ហាញបាន។

♦ តែង "អូសទាញដៃ" ទៅកាន់វត្ថុដែលខ្លួនចង់បាន។

♦ អាចនិយាយឃ្លា ដដែលៗ ម្តងហើយ ម្តងទៀត។

*លំបាកក្នុងការប្រាស្រ័យទាក់ទងជាមួយមនុស្ស វត្ថុ និងព្រឹត្តិការណ៍ផ្សេងៗ៖*

♦ មានការលំបាកក្នុងការបង្កើតមិត្តភក្រ្តិ

♦ ពិបាកអានយល់នូវទឹកមុខមនុស្ស

♦ អាចមិនសម្លឹងមុខសមាជិកគ្រួសារ ឬអ្នកដទៃ។



*មានចលនា ឬអាកប្បកិរិយាចំឡែក និងដដែលៗ*



♦ សម្លឹងមើលពិដាន ឬកង្ហារវិលជាច្រើនម៉ោង រៀបវត្ថុជាជួរ...

♦ និយាយ ឬធ្វើសម្លេងដដែលៗ

♦ បង្វិលខ្លួន យោគខ្លួន លោតរលាស់ម្រាមដៃ ស្រែក។

*បញ្ហាផ្សេងៗ៖*



* បញ្ហាវិញ្ញាណ៖

♦ អាចងាយនឹងឈឺចាប់

♦ ខ្លាចសម្លេងខ្លាំង (សម្លេងស្វាន) ឬស្ថានភាពថ្មីណាមួយ។

♦ដើរចុងជើង

* អាកប្បកិរិយាធ្វើបាបខ្លួនឯង៖

♦ អាចខាំដៃ បោកក្បាល ទាញសក់ខ្លួនឯង។

* កុមារខ្លះអាចមានបញ្ហាក្រពះ-ពោះវៀន៖

♦ រាគរូស អាការៈទល់លាមក អាហារមិនរំលាយនៅក្នុងលាមក ក្អួតញ៉ឹកញាប់ និងរើសចំណីអាហារ។

* បញ្ហាចលនា៖

♦ ពិបាកចាប់យកវត្ថុតូចៗដោយម្រាមដៃ

♦ មានភាពមិនធម្មតានៃចលនាដៃ ជើង

♦ ពុំមានលំនឹង និងពិបាកសំរបសំរួលចលនា។

អូទីស្សឹមភាគច្រើនមានពុទ្ធិបញ្ញា(ការយល់ដឹង) ធម្មតា ឯខ្លះទៀតមានការយល់ដឹងទាប (អាប់បញ្ញា)។

## តើអូទីស្សឹមកើតនៅលើនរណាខ្លះ?

អូទីស្សឹមកើតមាននៅលើ កុមារ១នាក់ ក្នុងចំណោមកុមារចំនួន110នាក់។ ក្មេងប្រុសកើតមានច្រើនជាងក្មេងស្រីពី៤ ទៅ៥ដង។

## តើគេធ្វើរោគវិនិច្ឆ័យអូទីស្សឹមបានដោយរបៀបណា?

មិនមានតេស្តវេជ្ជសាស្ត្រណាមួយដែលអាចកំណត់រោគវិនិច្ឆ័យអូទីស្សឹមបានទេ។ អ្នកឯកទេសដែលមានការបណ្តុះបណ្តាលជាក់លាក់ធ្វើរោគវិនិច្ឆ័យអូទីស្សឹមដោយផ្អែកលើ៖

♦ ការសង្កេតពីរបៀបនិយាយ និងអាកប្បកិរិយារបស់កុមារ ហើយប្រៀបធៀបទៅនឹងកុមារដទៃទៀតដែលមានអាយុស្របាលគ្នា។

♦ ការសន្ទនាជាមួយកុមារ និងការសួរសំណួរមួយចំនួនទៅឪពុកម្តាយ និងអ្នកថែទាំដទៃទៀតរបស់គាត់។



## តើអូទីស្សឹមកើតឡើងដោយសារអ្វី?

មូលហេតុពិតប្រាកដនៃអូទីស្សឹមមិនទាន់បានដឹងច្បាស់លាស់នៅឡើយទេ។ មានកត្តាជាច្រើនដែលអាចរួមចំណែកបង្កឱ្យកើតមានអូទីស្សឹម រួមទាំងកត្តាហ្សែនដែលបង្កើតកុមារ និងកត្តាបរិស្ថានដែលកុមាររស់នៅ។ ហានិភ័យនៃការកើតមានអូទីស្សឹម មានកាន់តែខ្ពស់ប្រសិនបើមានសមាជិកគ្រួសារមានអូទីស្សឹម។

តាមការស្រាវជ្រាវបានបង្ហាញថា អូទីស្សឹមមិនមែនបណ្តាលមកពីការចិញ្ចឹមបីបាច់កូន មិនបានល្អនោះទេហើយវា ក៏មិនមែនបណ្តាលមកពីការចាក់ថ្នាំបង្ការដែរ។